Australian Government
Australian Taxation Office

# ទទួលជំនួយដោយឥតគិតថ្លៃក្នុងការធ្វើរបាយការណ៍ពន្ធដាររបស់លោកអ្នក

**ប្រសិនបើលោកអ្នកត្រូវការជំនួយដាក់ពាក្យរបាយការណ៍ពន្ធដាររបស់លោកអ្នក, Tax Help (ជំនួយសេវាកម្មពន្ធដារ) ដោយឥតគិតថ្លៃរបស់ Australian Taxation Office’s (ATO) គឺមានជូន។**

## តើ Tax Help (ជំនួយពន្ធដារ) ជាអ្វី?

សេវាកម្មនេះគឺសម្រាប់បណ្ដាជនដែលត្រូវការជំនួយសម្រាប់ការត្រៀមរៀបចំ និងដាក់ពាក្យធ្វើរបាយការណ៍ពន្ធដាររបស់ពួកគេ។ ជំនួយពន្ធដារនេះគឺត្រូវបានផ្ដល់ជូនដោយបណ្ដាអ្នកជួយស្ម័គ្រចិត្តដែលបានទទួលការហ្វឹកហ្វឺនពីសំណាក់ស្ថាប័ន ATO។

សេវាកម្មនេះគឺមានជូនពីខែកក្កដាដល់ខែតុលានៅក្នុងតំបន់ឆ្ងាយៗជាច្រើន និងតាមក្រុងរដ្ឋបាលទាំងអស់នៃប្រទេសអូស្ត្រាលី។ នៅតាមទីកន្លែងខ្លះជំនួយពន្ធដារ Tax Help គឺមានជូនជាភាសាដទៃទៀតក្រៅពីភាសាអង់គ្លេស។

លោកអ្នកអាចជួបផ្ទាល់ជាមួយនឹងអ្នកជួយស្ម័គ្រចិត្ត Tax Help។ ប្រសិនបើការជួបមុខផ្ទាល់មិនអាចធ្វើទៅបានទេនោះ អ្នកស្ម័គ្រចិត្តអាចផ្ដល់ជំនួយពន្ធដារ Tax Help តាមអ៊ីនធើរណិត ឬតាមទូរសព្ទ។

## តើនរណាខ្លះអាចប្រើជំនួយពន្ធដារ Tax Help?

លោកអ្នកអាចប្រើសេវាកម្មជំនួយពន្ធដារ Tax Help នេះប្រសិនបើប្រាក់ចំណូលរបស់លោកអ្នកប្រហែលជា $60,000 ឬតិចជាងនេះសម្រាប់ឆ្នាំសារពើពន្ធ ហើយលោកអ្នកមិនបាន៖

- ធ្វើការជាអ្នកធ្វើការងារកុងត្រា (contractor), ឧទាហរណ៍ដូចជាអ្នកធ្វើការងារកុងត្រាជាអ្នកជូតសម្អាត (contract cleaner) ឬជាអ្នកបើកបររថយន្តតាក់ស៊ី (taxi driver)
- ដំណើរការអាជីវកម្ម ក្នុងនោះរួមបញ្ចូលទាំងពាណិជ្ជកររទោល
- ធ្វើជាដៃគូជំនួញអាជីវកម្ម (partnership) ឬក្នុងកិច្ចការអាណត្តិព្យាបាលភាព (trust)
- លក់ភាគហ៊ុន ឬក៏អចលនទ្រព្យវិនិយោគទុន
- ជាម្ចាស់កម្មសិទ្ធិអចលនទ្រព្យជួលឲ្យគេ
- មានពន្ធលើប្រាក់ចំណេញមូលធន (capital gains tax (CGT))
- ទទួលប្រាក់កម្រៃឈ្នួល (royalties)
- ទទួលប្រាក់ចែកចាយពីអាណត្តិព្យាបាលភាព (trust) ក្រៅតែពីមូលនិធិសោធនវិនិយោគដែលមានការគ្រប់គ្រង (managed fund)
- ទទួលប្រាក់ចំណូលពីបរទេស ក្រៅតែពីប្រាក់សោធនបរទេស (foreign pension) ឬក៏ប្រាក់បំណាច់ប្រចាំឆ្នាំ (annuity)។

## តើខ្ញុំអាចប្រើជំនួយពន្ធដារ Tax Help ដោយរបៀបណា?

សូមទូរសព្ទទៅ ATO តាមលេខ **13 28 61** ដើម្បីធ្វើការណាត់ជួបនៅឯមជ្ឈមណ្ឌល Tax Help ដែលនៅជិតលោកអ្នកជាងគេ។

ប្រសិនបើលោកអ្នកគ្មានសិទ្ធិទទួលបានជំនួយ Tax Help ទេនោះ លោកអ្នកនឹងត្រូវដាក់ពាក្យធ្វើរបាយការណ៍ពន្ធដារតាមវិធីផ្សេងទៀត។ លោកអ្នកអាចដាក់ពាក្យរបាយការណ៍ពន្ធដារតាមអ៊ីនធើរណិតដោយប្រើ myTax ឬក៏លោកអ្នកអាចប្រើភ្នាក់ងារពន្ធដារដែលបានចុះបញ្ជីឈ្មោះ (registered tax agent)។

## អ្វីដែលត្រូវនាំយកទៅជាមួយនៅពេលទៅជួបនឹង Tax Help

លោកអ្នកនឹងត្រូវការ៖

- ឈ្មោះគណនី និងលេខសម្ងាត់សម្រាប់ myGov – ប្រសិនបើលោកអ្នកមិនចាំព័ត៌មានលម្អិតរបស់ខ្លួន ឬគ្មានគណនីនេះទេ អ្នកជួយស្ម័គ្រចិត្ត Tax Help អាចជួយបាន
- ទូរសព្ទចល័តសម្រាប់ទទួលលេខកូដរបស់លោកអ្នកពី myGov
- ព័ត៌មានលម្អិតនៃគណនីធនាគាររបស់លោកអ្នក (លេខ BSB និងលេខគណនី)
- លេខពន្ធដារ (TFN) របស់លោកអ្នក
- លិខិតវាយតម្លៃពន្ធដារ (notice of assessment) នៃឆ្នាំណាមួយក្នុងអំឡុងពេល៥ឆ្នាំកន្លងទៅ
- របាយការណ៍ប្រាក់ចំណូលពីគ្រប់និយោជកទាំងអស់របស់លោកអ្នក
- បង្កាន់ដៃសម្រាប់ចំណាយផ្សេងៗទាក់ទងនឹងការងារ, ការបរិច្ចាគ ឬអំណោយផ្សេងៗ
- ព័ត៌មានលម្អិតអំពីការបង់ប្រាក់ជំនួយកូន (child support payments) ដែលលោកអ្នកបានបង់
- ព័ត៌មានលម្អិតអំពីប្រាក់ចំណូលរបស់ដៃគូ (ដែលបានរៀបការ ឬក៏រស់នៅជាមួយគ្នា de-facto) ឬក៏ការប៉ាន់ប្រមាណសមរម្យមួយ ប្រសិនបើលោកអ្នកបានមានដៃគូនៅពេលណាមួយក្នុងអំឡុងពេលនៃឆ្នាំសារពើពន្ធនេះ។

## កន្លែងទៅរកជំនួយ

សម្រាប់ព័ត៌មានបន្ថែម សូមចូលទៅមើលវិបសាយថ៍របស់ ATO នៅឯ ato.gov.au/TaxHelp (ជាភាសាអង់គ្លេស)។

## ធនធាននានា (ជាភាសាអង់គ្លេស)

- Income, deductions, offsets and records
- Deductions you can claim
- Your tax return
- Finding and using a tax practitioner
- Records you need to keep

**សេចក្តីប្រកាសមិនទទួលខុសត្រូវ (Disclaimer)**៖ ព័ត៌មាននេះគឺគ្រាន់តែព័ត៌មានសង្ខេបទូទៅប៉ុណ្ណោះ ហើយមានបច្ចុប្បន្នភាពនៅថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២០។

លោកអ្នកមានសិទ្ធិសេរីភាពនៅក្នុងការចម្លង, យកជាគំនិត, កែសម្រួល, បញ្ជូន និងចែកចាយឯកសារនេះតាមបំណងប្រាថ្នា (ប៉ុន្តែមិនត្រូវធ្វើក្នុងន័យណាមួយដែលបង្ហាញឲ្យជាគំនិតថា ATO ឬក៏រដ្ឋាភិបាលសហព័ន្ធ គាំទ្រលោកអ្នក ឬក៏សេវាកម្មរបស់លោកអ្នក ឬក៏ផលិតផលរបស់លោកអ្នកឡើយ)។